00966662

E138/1/10/1/5/9/3

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 12 / 2013
ម៉ោង (Time/Heure) : 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៣

ជូនចំពោះ: ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក

ពី: ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង មេធាវីការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ, ការិយាល័យសហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, អាណាព្យាបាលស្របច្បាប់របស់ អៀង ធីរិទ្ធ

កម្មវត្ថុ: ការអនុវត្តអនុសាសន៍របស់អ្នកជំនាញលើការថតស្កេន CT head លើលោកស្រី អៀង ធីរិទ្ធ

កាលពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងអ្នកជំនាញវេជ្ជសាស្ត្រដើម្បីអនុវត្តការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រលើ អៀង ធីរិទ្ធ រៀងរាល់ ០៦ ខែម្តង (ឯកសារ E138/1/10/1/5/9) ។ នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៣ អ្នកជំនាញវេជ្ជសាស្ត្រដែលបានទទួលការតែងតាំង (វេជ្ជបណ្ឌិត Ben VAN DEN BUSSCHE ដោយមានជំនួយពីវេជ្ជបណ្ឌិត គឹម ចាន់ថន) បានដាក់ជូនអង្គជំនុំជម្រះ នូវ "របាយការណ៍ស្តីពីការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រមកលើ អៀង ធីរិទ្ធ រៀងរាលប្រាំមួយខែម្តង ដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១៣" ("របាយការណ៍")

(ឯកសារ E138/1/10/5/9/2)។ អ្នកជំនាញវេជ្ជសាស្ត្រផ្តល់អនុសាសន៍ឱ្យធ្វើការស្កេន CT head ទៅលើលោកស្រី អៀង ធីរិទ្ធ ម្តងទៀត នៅក្នុងរយៈពេលប្រាំមួយខែខាងមុខនេះ (កថាខណ្ឌ២៨) ។

ដើម្បីអនុវត្តអនុសាសន៍នេះ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក សម្រប សម្រួលជាមួយក្រុមគ្រូពេទ្យដែលពិនិត្យព្យាបាល លោក ស្រី អៀង ធីរិទ្ធ រៀបចំឱ្យមានការថតស្កេន CT head នេះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន និងប្រគល់ឯកសារ CT head Scan ថតចម្លងមួយច្បាប់ទៅឱ្យក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ និងបន្ទាប់មកដាក់ឯកសារទាំងនោះមួយច្បាប់ទៅក្នុងសំណុំរឿង។